# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 778

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងសម្របសម្រួលបង្កើតនិងអភិវឌ្ឍន៍តំបន់កសិឧស្សាហកម្មក្នុងប្រទេសកម្ពុជា

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/01/26

កាលបរិច្ឆេទបញ្ចប់គម្រោង 31/12/28

៣. ចំណាយគម្រោងសរុប $100,000,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT Department of Agro-Industry

អង្គភាពទទួលខុសត្រូវ នាយកដ្ឋានកសិឧស្សាហកម្ម

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៣- ការលើកស្ទួយកសិកម្ម និងការអភិវឌ្ឍជនបទ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនឹងចូលរួមជំរុញទំនាក់ទំនងទីផ្សារនិងតម្លៃបន្ថែមទៅលើផលិតផលកសិកម្ម។ លើសពីនេះទៀត គឺរៀបចំអោយកសិករខ្នាតតូច ឬសមាគមន៍កសិករក្លាយជាសហគ្រិនខ្នាតមធ្យម និងធំ។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

**១១. វិស័យ** (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

Research and Extension Services

Livestock

Land Management

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ក្រចេះ, ត្បូងឃ្មុំ , ប៉ៃលិន, រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

- បង្កើតទំនាក់ទំនងទីផ្សារទាំងក្នុង និងក្រៅស្រុកតាមរយៈយន្តការកិច្ចសន្យាផលិតកម្មកសិកម្ម
- ជម្រុញអន្តរកម្មរវាងតួអង្គក្នុងខ្សែច្រវ៉ាក់ផលិតកម្ម និងតម្លៃបន្ថែមទៅលើផលិតផលកសិកម្ម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ និងការប្រកួតប្រជែងក្នុងតំបន់ និងអន្តរជាតិ
- បង្កើនការនាំចេញផលិតផលកសិកម្មកែច្នៃ រួមទាំងផលិតផលកែច្នៃថ្មីៗ ឱ្យបានស្មើ ១៥%នៅឆ្នាំ២០៣០

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

- បង្កើនសមត្ថភាពមន្ត្រីជំនាញ និងកសិករក្នុងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា
- បង្កើតទីផ្សារសម្រាប់ដំណាក់កាលទី១ របស់គម្រោង:
អនុវត្តការសិក្សាលទ្ធភាពពីតំបន់កសិឧស្សាហកម្មដែលមានសក្តានុពលនៅប៉ៃលិន ស្រុកស្នួលខេត្តក្រចេះ និងក្រុងភ្នំពេញ និងលទ្ធភាពនៅក្នុងប្រទេសដទៃទៀតដើម្បីប្រមូលទិន្នន័យសក្តានុពលលើការតំបន់កសិ-ឧស្សាហកម្មដែលមាននិរន្តរភាព។ ការសិក្សានេះផ្តល់នូវទិន្នន័យមូលដ្ឋានលើតំបន់ដែលមានស្រាប់/ ឬទីតាំងដែលមានសក្តានុពល(ដោយពិចារណាលើហេដ្ឋារចនាសម្ព័ន្ធទំនិញមានសក្តានុពល តម្រូវការទីផ្សារ កម្លាំងពលកម្ម ដី ជាដើម) នៅតាមខេត្ត/ ក្រុងគោលដៅនិងលទ្ធភាពនៃការរួមបញ្ចូលគ្នារវាងតំបន់កសិឧស្សាហកម្មនិងតំបន់សេដ្ឋកិច្ចពិសេសដែលកំពុងដំណើរការ។
- រៀបចំបង្កើត និងអនុវត្តយ៉ាងហោចណាស់តំបន់កសិឧស្សាហកម្មមួយដែលគួរស្ថិតនៅក្នុងក្រុងភ្នំពេញ ដោយផ្តោតលើផលិតផលសក្តានុពលបីប្រភេទក្នុងនោះរួមមានដំឡូងមី ស្វាយចន្ទី និងស្វាយ។
រៀបចំសិក្ខាសាលាដើម្បីប្រមូលផ្តុំគំនិតយោបល់នានានិងផ្សព្វផ្សាយព័ត៌មានរបស់គម្រោងក្នុងចំណោមអ្នកពាក់ព័ន្ធជាពិសេសវិស័យឯកជន។
ចាប់ផ្តើមការសម្របសម្រួលនិងគាំទ្រដល់ការបង្កើតនិងដំណើរការនៃតំបន់កសិ-ឧស្សាកម្មដោយក្រុមការងាររួមទាំងអង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន សហគ្រាសខ្នាតតូចនិងមធ្យម ស្ថាប័នរដ្ឋាភិបាល និងម្ចាស់ជំនួយជាដើម។
និងចាប់ផ្តើមបង្កើតតំបន់សហគ្រាសខ្នាតតូចនិងមធ្យមក្នុងតំបន់សេដ្ឋកិច្ចពិសេសនៅរាជធានីភ្នំពេញ។
ដំណាក់កាលទី២ របស់គម្រោង:
រៀបចំបង្កើត និងអនុវត្តតំបន់កសិឧស្សាហកម្មនៅស្រុកស្នួល ខេត្តក្រចេះ និងខេត្តប៉ៃលិន ដោយផ្តោតលើដំណាំសក្តានុពល៣ប្រភេទ (សម្រាប់ខេត្តក្រចេះ៖ ដំឡូងមី, គ្រាប់ស្វាយចន្ទី, ម្រេច និងខេត្តប៉ៃលិន៖ ផ្លែមៀន ដំឡូងមី ពោត)។
នៅក្នុងដំណើរការនៃការបង្កើតតំបន់កសិឧស្សាហកម្ម មានសមាសភាពសំខាន់ៗដូចក្រោម:
2.1 គោលនយោបាយនិងគោលការណ៍ណែនាំ:
2.1.1 រៀបចំបង្កើតគោលការណ៍ណែនាំស្តីពីតំបន់កសិឧស្សាហកម្ម
2.1.2 រៀបចំបង្កើតបញ្ជីសមាសភាពសមាជិកSME ដែលមានស្រាប់និងសក្តានុពល
2.1.3 រៀបចំបង្កើតគោលនយោបាយស្តីពីកិច្ចសន្យាផលិតកម្មកសិកម្ម
2.1.4 រៀបចំបង្កើតគោលនយោបាយស្តីពីមុខដំណាំកសិកម្មសក្តានុពល
2.2 សកម្មភាពដោយផ្ទាល់

2.2.1 រៀបចំវេទិកាសាធារណៈសម្រាប់សហគមន៍កសិកម្ម សហគ្រិន ក្រុមហ៊ុន រោងចក្រ និងកសិករ ស្តីពីតំបន់កសិឧស្សាហកម្ម
2.2.2 គៀងគរការគាំទ្រពីវិស័យឯកជន ស្ថាប័នរដ្ឋាភិបាល
និងស្ថាប័នពាក់ព័ន្ធនានាក្នុងការបង្កើតតំបន់កសិឧស្សាហកម្មតាមរយៈការចុះជួបដោយផ្ទាល់ វគ្គសិក្សា សិក្ខាសាលា វេទិកា ការបណ្តុះបណ្តាលផ្សេងៗ
2.2.3 ការរៀបចំនិងចងក្រងកសិករជាក្រុម និងបណ្តុះបណ្តាលបន្ថែមលើជំនាញជាសហគ្រិននិងជំនាញចរចាផងដែរ។
2.2.4 រៀបចំវេទិកាជម្រុញការយល់ដឹងស្តីពីកិច្ចសន្យាផលិតកម្មកសិកម្ម
និងចុះសិក្សាផ្ទាល់នូវទីតាំងដែលអនុវត្តជោគជ័យតាមក្រុមហ៊ុនសហគមន៍
2.2.5 វេទិកាផ្គូផ្គងរវាងអ្នកផលិតនិងអ្នកទិញ និងការតាមដានការអនុវត្តកិច្ចសន្យា
2.2.6 វគ្គបណ្តុះបណ្តាលស្តីអំពីបច្ចេកទេសក្រោយប្រមូលផល
2.2.7 បង្កើតមជ្ឈមណ្ឌលកែច្នៃ
2.3 ការសម្របសម្រួល:
2.3.1 បង្កើតតំបន់អេកូទេសចរណ៍នៅតំបន់កសិឧស្សាហកម្ម
2.3.2 លើកកម្ពស់ចង្វាក់ផលិតកម្មនិងតម្លៃបន្ថែមលើផលិតផលកសិកម្ម
2.3.3
ការស្រាវជ្រាវនិងការអភិវឌ្ឍន៍លើការផ្តល់ហិរញ្ញប្បទានដោយសហការជាមួយនឹងស្ថាប័នស្រាវជ្រាវជំនាញនៅកម្ពុជាដោយផ្តោតសំខាន់លើវិធីនៃការស្រាវជ្រាវដែលមានការចូលរួមពីកសិករនិងផ្អែកលើទិន្នន័យរបស់កសិករ(FPR)។
2.3.4 ធ្វើការសម្របសម្រួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC
រៀបចំសិក្ខាសាលាស្តីពីសហគ្រាសធុនតូចនិងការវិនិយោគក្រៅប្រទេសដោយផ្ទាល់ដើម្បីលើកកម្ពស់ផលិតផលកសិកម្មទៅតាមតម្រូវការទីផ្សារក្នុងស្រុកនិងអន្តរជាតិ
2.3.5 ជំរុញកសិករឱ្យក្លាយជាបណ្តាញអាជីវកម្មនៃកសិករ
2.3.6 លើកកម្ពស់ការយល់ដឹងសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុក(LED) ក្នុងការវិនិយោគដែលទាក់ទងទៅនឹងលក្ខណៈទូទៅ
2.3.7 ការបង្កើតតំបន់ដីបន្ថែមសម្រាប់ដំណាំដែលមានសក្តានុពលដើម្បីធានាការដាំដុះនិងប្រមូលផលតាមសហគមន៍
គម្រោងនេះជាការអនុវត្តក្នុងភាពជាដៃគូ(PPP) រវាង វិស័យសាធារណៈ វិស័យឯកជន និងអ្នកផលិត។ តាងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានកសិ-ឧស្សាហកម្មជាអ្នកដឹកនាំគម្រោង។
ជាការពិតណាស់វិស័យឯកជនក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតនិងអភិវឌ្ឍន៍តំបន់កសិឧស្សាហកម្មនៅកម្ពុជារួមទាំងកសិករឬអ្នកផលិតផងដែរ។ គម្រោងនេះអនុវត្តនៅក្នុងយន្តការមុំបី។
ដំណាក់កាលទី៣ នៃគម្រោង:
នៅក្នុងដំណាក់កាលទី៣ នៃការអនុវត្តគម្រោង តំបន់កសិឧស្សាហកម្មដែលបង្កើតឡើងនៅក្នុងភ្នំពេញ ប៉ៃលិន និងស្រុកស្នួល ខេត្តក្រចេះត្រូវរៀបចំពង្រីកបន្ថែម។
រៀបចំបង្កើតគោលនយោបាយនិងយន្តការដើម្បីធ្វើឱ្យសមហេតុផលសម្រាប់ការសម្របសម្រួលតំបន់កសិ-ឧស្សាហកម្ម
តាមរយៈការធ្វើការសិក្សា ដើម្បីលើកកម្ពស់និងគាំទ្រដល់ដំណើរការវិវត្តទៅរកកសិឧស្សាហកម្ម4.0
រៀបចំសិក្ខាសាលាបញ្ចប់គម្រោងដោយមានឯកសារណែនាំដើម្បីចែករំលែកបទពិសោធន៍ បញ្ហាប្រឈម
និងអនុសាសន៍ក្នុងការបង្កើតតំបន់កសិឧស្សាហកម្មនៅថ្ងៃអនាគត។
ការតាមដាននិងវាយតម្លៃគម្រោង:
រៀបចំចងក្រងគោលការណ៍ណែនាំសម្រាប់តាមដាននិងវាយតម្លៃ ដែលរៀបរាប់លម្អិតស្តីអំពី លទ្ធផលរបស់គម្រោង
សកម្មភាពគម្រោងនិងសូចនាករ និងវិធីសាស្ត្រក្នុងការវាស់វែង ដើម្បីត្រួតពិនិត្យ
លទ្ធភាពដែលសម្រេចបានដោយផ្ទៀងផ្ទាត់ជាមួយគោលដៅរបស់គម្រោង1,2និង3។
រៀបចំការស្ទង់មតិដើម្បីកំណត់កម្រិតពេញចិត្តរបស់អ្នកពាក់ព័ន្ធលើការអនុវត្តគម្រោង។
ផលិតផលកសិកម្មតាមរយៈការព្រមព្រៀងរវាងអ្នកផលិត និងអ្នកទិញមុនពេលដំណើរការផលិត
- គោលនយោបាយលើកទឹកចិត្តកសិករ និងអ្នកវិនិយោគ ក្នុងការផលិត និងការនាំចេញកសិផល
- កាត់បន្ថយ និងដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ
- ការគាំទ្របច្ចេកទេសទាំងក្នុងផលិតកម្ម និងការកែច្នៃនាំចេញ
- ការចុះបញ្ជីទទួលស្គាល់ និងយន្តការតាមដានវាយតម្លៃការអនុវត្តផលិកម្មតាមកិច្ចសន្យា

- យន្តការផ្សេងទៀតនៃដំណើរការរបស់គណៈកម្មាធិការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

សេដ្ឋកិច្ចកម្ពុជាបានទទួលនូវអត្រាកំណើនដ៏សំខាន់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ
ដោយវិស័យវាយនភ័ណ្ឌដែលមានដល់70%នៃការនាំចេញសរុប។
ទោះជាយ៉ាងណាក៏ដោយវិស័យកសិកម្មនៅតែមានសារៈសំខាន់ក្នុងការទាញយកកម្លាំងពលកម្មនិងការងារដែលតម្រូវអោយចូលរួមចំណែកចំនួន54,9% នៃកម្លាំងពលកម្មទាំងអស់(តួលេខរបស់អាស៊ានឆ្នាំ២០១៨)។
ការពិតកំណើនកសិកម្ម(៨,៧%)ក្នុងមួយឆ្នាំសម្រាប់ឆ្នាំ២០០៤-២០១២, ទិន្នន័យធនាគារពិភពលោកឆ្នាំ ២០១៥)
ស្ថិតក្នុងប្រទេសដែលមានអត្រាខ្ពស់ក្នុងពិភពលោក ហើយបានចូលរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រ។
ក្នុងឆ្នាំ២០០៧ដល់ឆ្នាំ២០១១
ចំនួនប្រជាពលរដ្ឋក្រីក្របានធ្លាក់ចុះពី៧ទៅ៣លាននាក់ដោយ៦០%នៃការកាត់បន្ថយនោះគឺដោយសារវិស័យកសិកម្ម។
ទោះយ៉ាងណាក៏ដោយកសិករភាគច្រើនដែលបានរួចផុតពីភាពក្រីក្រទទួលបានប្រាក់ចំណេញតិចតួចហើយភាពងាយរងគ្រោះរបស់ពួកគេនៅខ្ពស់។
ភាពងាយរងគ្រោះនេះគឺខ្ពស់បំផុតសម្រាប់កសិករខ្នាតតូចខណៈដែលសេវាលើកកម្ពស់និងអភិវឌ្ឍន៍កសិកម្មមិនទាន់ឈានដល់កម្រិតធំឡើយ។
តំបន់កសិឧស្សាហកម្មមិនទាន់បានបង្កើតឡើងនៅឡើយក្នុងប្រទេសកម្ពុជាខណៈដែលវាមានសារៈសំខាន់និងចាំបាច់ខ្លាំងក្នុងការគ្រប់ដណ្ដប់លើខ្សែចង្វាក់ផលិតកម្មនិងការបន្ថែមតម្លៃលើផលិតផលកសិកម្ម។ តំបន់កសិឧស្សាហកម្មនិងការពង្រីកតំបន់
នឹងបង្កើនចំណែកការនាំចេញផលិតផលកសិកម្មកែច្នៃ(រាប់បញ្ចូលទាំងផលិតផលកែច្នៃថ្មី)ដល់១២%
នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥ (IDP2015)
ហើយគម្រោងនេះនឹងរួមចំណែកដល់ការសម្រេចគោលដៅរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់កម្ពុជាឱ្យមានសេដ្ឋកិច្ចដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០និងជាប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកទទួលផលផ្ទាល់៖ កសិករ សមាគមន៍កសិកម្ម សហគ្រិន ម្ចាស់ក្រុមហ៊ុន រោងចក្រ
អ្នកទទួលផលមិនផ្ទាល់៖ ស្ត្រី ជនពិការ កុមារ

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទានចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះនឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើតការងារសម្រាប់កសិករជុំវិញតំបន់អនុវត្តគម្រោង
និងផលិតផលកសិកម្មត្រូវបានធានាស្របតាមតម្រូវការទីផ្សារ

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? មាន

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស ការបន្សាំ

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

| | |
|---|---|
| តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? | **មាន** |
| ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស | **ការត្រៀម** |

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ស្ត្រីងាយរងគ្រោះនឹងអំពើហឹង្សាក្នុងគ្រួសារត្រូវបានកាត់បន្ថយតាមរយៈការចូលរួមរបស់ស្ត្រីក្នុងសង្គម។ ស្ត្រីនឹងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះ និងក្លាយជាអ្នករកចំណូលសម្រាប់គ្រួសារតាមរយៈចង្វាក់ផលិតកម្ម និងការកែច្នៃផលិតផលកសិកម្ម។ គម្រោងនេះមាន ៩ ទិ្វពលវិជ្ជមានទៅលើតួនាទី និងជីវភាពរបស់ស្ត្រី ព្រោះគម្រោងនេះត្រូវការការចូលរួមរបស់ស្ត្រីយ៉ាងហោចណាស់ 45%នៃអ្នកចូលរួមសរុបនៅក្នុងសកម្មភាពគម្រោងទាំងអស់ដូចជាការបណ្ដុះបណ្ដាល វេទិកា សិក្ខាសាលា។ល។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រៅពីមន្ត្រីអចិន្ត្រៃយ៍របស់ខ្លួន ក្រសួងកសិកម្មនឹងជ្រើសរើសអ្នកពិគ្រោះយោបល់ដែលជាទីប្រឹក្សាថ្នាក់ជាតិ និងអន្តរជាតិដែលមានជំនាញក្នុងការបង្កើត និងអភិវឌ្ឍតំបន់កសិឧស្សាហកម្ម ដើម្បីបំពេញការងារបន្ថែម។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្ដាលឲ្យមាន ការពន្យាពេលក្នុងការអនុវត្តគម្រោង។)

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្ដល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្ដានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លាអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: